# ប្រុសស្អាតមកដល់នាកណ្ដាលរាត្រី-Bi anca

នៅពេលដែលគេដកខ្លួនចេញ ខ្ញុំនៅតែមានអារម្មណ៍ថា នៅមានបបូរមាត់របស់គេនៅពីលើខ្ញុំ។ ខ្ញុំត្រូវការបន្ថែមទៀត! ច្រើនទៀត! យ៉ាងត្រេកត្រអាល។

«ម៉េចក៏ខ្ញុំចង់បានអ្នកខ្លាំងម្ល៉េះ?» គេសួរមកទាំងដកដង្ហើមធំតឹងតែង។

ខ្ញុំគួរតែប្រាប់គេពីអារម្មណ៍ពិតខ្លួនឯងដែរទេ? ទេ! ខ្ញុំមិនគួររីករាយភ្លើតភ្លើននឹងរឿងនេះច្រើនហួសហេតុនោះទេ  ប៉ុន្តែ....អាក្រក់បំផុត ខ្ញុំនៅតែបន្តសួរខ្លួនឯងនូវសំណួរដដែលៗនោះដូចគេដែរ«ហេតុអ្វីគេដូចជាពិសេសម្ល៉េះ?»។

មេបិសាចមិនរង់ចាំខ្ញុំឆ្លើយតបទៅគេទេ។ ផ្ទុយទៅវិញ គេលូកដៃហើយឈានចូលមកជិតនឹងខ្ញុំម្ដងទៀត ថែមបានចាប់ច្បាមក្រសោបខ្ញុំចង្កេះ។

គេលើកខ្ញុំឡើង។

ដោយសភាវគតិ ខ្ញុំរុំជើងជុំវិញចង្កេះរបស់គេ។ ប្រុសម្នាក់នេះ មិនព្រមបង្អង់រង់ចាំមួយភ្លែតណាទៀតឡើយ គេឱនមកថើប ខាងខ្ញុំវិញក៏លាបបូរមាត់ដើម្បីទទួលយកអណ្ដាតសើមរបស់គេទៀត។

ថើបរោលរាលផង គេដើរថយក្រោយផង។

គេបានលើកយកខ្ញុំមករកសាឡុងនៅជ្រុងជញ្ជាំងផ្ទះជាមួយនឹងការដកដង្ហើមដ៏រំភើបរវាងពួកយើង។ គ្រប់យ៉ាង រួមទាំងពេលវេលានិងការពិតក្នុងលោកនេះបានជាប់គាំង។ យើងលែងខ្វល់ហើយ! ពួកយើងដួលជាមួយគ្នាមកលើសាឡុង ទម្ងន់ខ្លួនរបស់គេបានសង្កត់មកគ្រប់គ្រងពីលើខ្ញុំ។

ខ្ញុំអាចមានអារម្មណ៍ថា អង្គជាតិរឹងរបស់គេចង្អុលប៉ះផ្ទត់ពោះរបស់ខ្ញុំ។ ឯគេវិញកំពុងថើបខ្ញុំដោយមិនចង់ឈប់ ធ្វើហាក់ដូចជាជីវិតរបស់យើង ការរស់មានដង្ហើមរបស់យើងទាំងពីរ ពឹងផ្អែកលើស្នេហាមួយនេះ។

ខ្ញុំលបគិតពីរ៉ូសនិងអ្នកដទៃ។

ពេលពួកគេមកវិញ ខ្ញុំនឹងលាក់លៀមរឿងអស់ទាំងនេះដោយអាម៉ាស់។ ពួកអម្បូរបន្តវេន មិនសូវដេកយប់ទេ។ ពួកគេធ្វើការក្រៅនៅពេលយប់។ តែរ៉ូសបានសន្យានឹងខ្ញុំរួចហើយ ថានាងមិននិយាយអំពីការមកដល់នៃមេបិសាចម្នាក់នេះទេ។

ហ៊ឹម! ខ្ញុំមិនចង់គិតអ្វីក្នុងពេលនេះឡើយ។ គេចាប់លាតជើងរបស់ខ្ញុំ ហើយខ្ញុំក៏ព្រមនៅស្ងៀមបញ្ជាក់ថា គេត្រូវបាន....អនុញ្ញាត។ ម្រាមដៃគេទន់ល្មើយ ខណៈរាងកាយខ្ញុំបានស្វាគមន៍វាចូលទៅក្នុងផ្ទត់រំអិលរលោងអាថ៌កំបាំងនិងស្រស់ស្អាតរបស់ខ្ញុំ។ គេកំពុងលលេងស្វែងយល់អំពីខ្ញុំ ដូចជាគេទុកខ្ញុំនេះ ថាជាឧបករណ៍ដ៏ល្អបំផុតក្នុងលោកដែលអាចញ៉ាំងគេឱ្យឈ្លក់វង្វេងបាន។

ហើយ....មេបិសាចម្នាក់នេះ គេដឹងពីរបៀបលេងរាងកាយខ្ញុំឱ្យបោកបាចបានយ៉ាងល្អឥតខ្ចោះ។ ខ្ញុំកំពុងអណ្តែតត្រសែតជាមួយការមានអារម្មណ៍រីករាយហួសហេតុ។ វាជាអារម្មណ៍នៃការទទួលយកក្តីរំភើបច្រើនឡើងៗ មួយស្រទាប់ហើយមួយផ្នត់ទៀត គឺច្រើនលើសពេកណាស់ក្នុងការទ្រាំទ្រ តែរាងកាយខ្ញុំពិតជាលោភចង់បាន។

តួខ្លួនទាំងមូលរបស់ខ្ញុំញាប់ញ័រនៅក្រោមការប៉ះដ៏ប៉ិនប្រសប់របស់គេ។ ចង្វាក់បេះដូងរបស់ខ្ញុំផ្ទាល់កំពុងតែបន្ទរនៅក្នុងចិត្តរបស់ខ្ញុំ ក្នុងកម្រិតដែលខ្ញុំមិនដែលគិតថាអាចឱ្យអ្នកណាឮសំឡេងតណ្ហានេះបានជាដាច់ខាត។

ភ្លាមៗនោះគេដកខ្លួនចេញ ហើយសម្លឹងមើលមកប្រស្រីភ្នែករបស់ខ្ញុំ។ បបូរមាត់របស់គេត្រូវបានបំបែកចេញពីគ្នាជាមួយស្នាមញញឹមពេញចិត្ត ភ្នែកគេចេញពន្លឺ ជាភាពភ្លឺចិញ្ចាចនៃសុដុមរមនាក្នុងជីវភាពស្នេហា។

គេខ្សឹបប្រាប់ខ្ញុំថា៖

«ប្រាប់! ប្រសិនបើចង់ឱ្យខ្ញុំឈប់!»

ខ្ញុំភ្ញាក់ផ្អើលនឹងសមត្ថភាពរបស់គេក្នុងការដកខ្លួនមកជាសុភាពបុរសក្នុងពេលវេលារបៀបនេះ។ ម្យ៉ាងទៀតគេមិនឃើញទេអី ថារាល់ចន្លោះនៃរាងកាយរបស់ខ្ញុំបានបញ្ចេញភាពត្រូវការ និងកំពុងចរចាប្រាប់គេថា គេនេះកំពុងធ្វើអ្វីដែលខ្ញុំពិតជាចង់ឱ្យគេធ្វើ។

«កុំឈប់» ខ្ញុំខ្សឹបតបវិញអង្វរករខ្សាវៗ។

ជំនួសឱ្យការឆ្លើយតប គេលូកមកទាញរុញកូនខោកំប៉ិតរបស់ខ្ញុំទៅចំហៀង។ ខ្ញុំមានអារម្មណ៍ថា ម្រាមដៃរបស់គេចូលចិត្តរុករកនិងលលេងជាមួយផ្នត់សើមរបស់ខ្ញុំធ្វើឱ្យខ្ញុំចាញ់ រមួល និងថ្ងូចថ្ងូរ។

កន្លងមក ខ្ញុំមិនដែលមាននរណាម្នាក់ដែលអាចមកប៉ះពាល់នៅទីនោះទេ សូម្បីកន្លែងផ្សេងក្តី។ ខ្ញុំមិនដែលគិតថា នេះជាកាយវិការអារម្មណ៍ល្អថ្នាក់នេះសោះឡើយ។

គេជាមេបិសាចតែគេមិនបានឃោរឃៅ បែរជាមានសមានចិត្តទន់ភ្លន់និងយឺតៗអត់ធ្មត់បំផុត។ បបូរមាត់របស់គេនៅលើកំពូលរបស់ខ្ញុំ ខណៈដែលម្រាមដៃរបស់គេគូសវាសជារង្វង់ថ្នមៗជុំវិញបបូរមាត់ក្រោម។

ខ្ញុំស្រែករំជួលចិត្តនិងមានសភាពញាប់ញ័រ។

ខណៈនេះខ្ញុំឮសំឡេងសើមៗ ពេលគេរុញខ្លួនគេចូលមករកល្អាងរបស់ខ្ញុំ ហើយរំកិលម្តងបន្តិចៗមកក្នុង។

ខ្ញុំគិតថា ឈឺ! រាងកាយនេះបញ្ជាក់ពីអារម្មណ៍ចម្លែក មិនចង់ស្វាគមន៍ព្រោះឈឺ! ប៉ុន្តែ...ផ្ទុយពីនោះរាងកាយនិងទ្រនុងរបស់ខ្ញុំកាន់តែលាតសន្ធឹងដើម្បីសម្រុះសម្រួល ទទួលយកគេ។

ពេលគេចូលមកកាន់តែជ្រៅ ខ្ញុំក៏ហក់ឡើងទទួលយកជាសង្វាក់ៗ។ ការឈឺចាប់លាយឡំនឹងភាពរំភើបរីករាយគឺជាការរួមបញ្ចូលគ្នាដ៏ល្អឥតខ្ចោះនិងពិបាកបរិយាយ។

ពេលរាងកាយសង្ហារបស់គេក្លាយមកជារបស់ខ្ញុំ មកសំងំនៅខាងក្នុងខ្លួនខ្ញុំ ធ្វើឱ្យខ្ញុំញាប់ញ័រដោយសេចក្តីត្រូវការ ដោយរំពឹងថា នេះជាស្នេហាដែលខ្ញុំចង់បានណាស់ គឺគិតអំពីរឿងនេះជាយូរណាស់មកហើយ។

វាបានមកដល់ពិតមែន ហើយជាមួយនឹងបុរសដ៏មានថាមពលម្នាក់ដែលញាំងឱ្យខ្ញុំលោភលន់គិតថា ខ្ញុំត្រូវការបន្ថែមទៀតជានិច្ចឱ្យគេចូលមកជាចំណុះខ្ញុំ ជាកម្មសិទ្ធិនិងជាបុរសក្នុងជីវិតខ្ញុំ។

ខ្ញុំបានបោះបង់ចោលរាល់សម្តីរបស់រ៉ូស «គេមិនត្រឹមជាបិសាចធម្មតា តែ.....ជាមេបិសាច!»

ពេលគេជំរុញចូលបន្ថែមដល់តែខ្ញុំស្រែកនិងអង្វរ មានអារម្មណ៍ថា រាងកាយផ្នែកក្នុងរបស់ខ្ញុំក៏បឺតជញ្ជក់យកគេ។ ច្បាមយកគេ .....មានអារម្មណ៍ល្អណាស់។

«អូនសម្លាញ់!» គេខ្សឹបរអ៊ូរទាំដោយស្នេហា ជាសព្ទសំឡេងធ្វើឱ្យខ្ញុំកាន់តែកក់ក្តៅ «បងចង់ធ្វើឱ្យអូនបានសុខនិងមានអារម្មណ៍ល្អ»។

គេបន្តចេញនិងចូលដោយថ្នមៗ បន្ថែមម្រាមដៃលេងគ្រប់ទីតំបន់ទៀត ខ្ញុំឮសំឡេងខ្លួនឯងថ្ងូរដោយក្តីរីករាយ។ ខ្ញុំដកបបូរមាត់ចេញពីគេនិងថ្ងូរតិចៗ ហើយខាំបបូរមាត់ខាងក្រោម។ ខ្ញុំបិទភ្នែកសុខសាន្តតែចង់ឃើញមុខរបស់គេ ចង់ដឹងថាតើគេបានសុខសាន្តដែរឬក៏ទេ?

គេក្រហមដោយភ្លើងតណ្ហា គេសម្លឹងខ្ញុំនិងញញឹមហើយគេបន្តការងាររបស់គេជានិច្ច។

ពេលវេលាកន្លងផុតទៅ។ មួយវិនាទីក្លាយជារយៈពេលពេញមួយម៉ោង។ រាងកាយរបស់ខ្ញុំមានប្រតិកម្មតាមរបៀបដែលខ្ញុំមិនដែលគិតថាអាចទៅរួច។ គេបន្តត្រដុសថើបទ្រូង ក និងដើមដៃរបស់ខ្ញុំខ្លាំងឡើងៗ ហើយភ្លាមៗនោះខ្ញុំក៏ផ្ទុះដល់កំពូល។

ខ្ញុំកប់មុខខ្ញុំចូលក្រោមកញ្ចឹងកគេ ថែមថ្ងូរតិចៗដកដង្ហើមធូរស្រាល។ កម្តៅផ្ទុះចេញពីកន្លែងជ្រៅៗនៅក្នុងស្នូលរបស់ខ្ញុំហើយលោតមកកម្តៅពេញរាងកាយទាំងមូលពីលើដល់ក្រោម ធ្វើឱ្យខ្ញុំចំណាយអស់ទាំងស្រុងនូវថាមពលរបស់ខ្លួន។

គេបន្តថើបញីទីតាំងនានារបស់ខ្ញុំថ្នមៗប្រើម្រាមដៃដោយស្រលាញ់ ខណៈមានអ្វីមួយប្រាប់ខ្ញុំថា យើងមិនទាន់រួចរាល់ទេ! នៅ នៅឡើយទៀត! គេមិនទាន់រួចរាល់ទេ!

បន្ទាប់មក ពិតជាដូចសំឡេងរបស់បេះដូង គេកំពុងបន្តធ្វើអ្វីមួយដែលមិននឹកស្មាន គេខ្សឹបសួរ៖

«បងបីអូនទៅគេងបានទេ?»

ខ្ញុំងក់ក្បាលភ្លាមដោយសម្លឹងមើលទៅភ្នែកស្រទន់ៗត្រង់ស្លូជិតគ្នា។

ម្រាមដៃខ្ញុំចង្អុលឡើងលើ។ គេយល់។ គេចាប់ខ្ញុំនៅក្នុងរង្វង់ដៃហើយបីនាំខ្ញុំឡើងជណ្ដើរសំដៅទៅបន្ទប់គេង។ តាមផ្លូវ ខ្ញុំមិនអាចដកភ្នែកពីស្លាកស្នាមឆ្នូតលើមុខដ៏សង្ហារបស់គេបានទេ។

សម្លាកនេះគួរឱ្យចាប់អារម្មណ៍។ វាជាផ្នែកមួយនៃរាងកាយកក់ក្ដៅនិងសិចស៊ីរបស់គេ ចិត្តខ្ញុំចង់ដឹងអំពីដំណើរដើមទង អត្ថន័យនៃសម្លាកនេះ ចង់ដឹងគ្រប់យ៉ាងទាំងអស់អំពីជីវិតរបស់គេ។

ក្នុងរង្វង់រាងកាយគេ ខ្ញុំខំទប់ទល់នឹងការល្បួងនៃភាពស្រើបស្រាល តែខ្ញុំឱបកគេ ញញឹមដាក់គេ។

គេដាក់ខ្ញុំថ្នមៗមកលើគ្រែហើយលើកខ្លួនគេឡើងបន្តិច ហាក់ដូចជា ចង់សំកាំងមើលមកខ្ញុំ។

ស្នាមញញឹមដ៏ពិសេសមួយដែលគេឱ្យមកពេលនេះកំពុងញ៉ាំងឱ្យបេះដូងនឹងនររបស់ខ្ញុំរលាយ។

វាមិនត្រឹមតែតណ្ហាទេរវាងយើង តែ.....ជាតំណភ្ជាប់ដ៏ជ្រៅមួយអាថ៌កំបាំងនិងមានអានុភាព។

នៅពេលខ្ញុំចង់ថើបគេជាខ្លាំង មុននឹងខ្ញុំអាចសម្រេចចិត្តធ្វើ គេឱនឈ្ងោកមកលេបបបូរមាត់ខ្ញុំម្ដងទៀត។ អណ្ដាតរបស់យើងរាំវិលចូលគ្នា ខណៈដែលប្រាណធំរបស់គេនៅពីលើខ្ញុំ។ ខ្ញុំរុំជើងរបស់ខ្ញុំជុំវិញគេ ដូចជាខ្ញុំមិនចង់ឱ្យគេទៅណាចោលទេ។

ខ្ញុំពិតជាមិនទទួលយកបានមែន បើគេសុខៗក៏ចាកចេញ។

គេមិនទៅទេ! យើងទាំងពីររមូរចូលគ្នា ថើបគ្នាដោយរាងកាយបញ្ចេញកម្ដៅកាន់តែខ្លាំង។ សម្លៀកបំពាក់របស់យើងហោះចេញដោយភាពរីករវ។ រូបកាយរបស់គេទាំងលើដល់ក្រោម គឺជារូបកាយមហាបុរស។ ខ្ញុំស្ទើរតែដកដង្ហើមធំ ស្រែករំភើប ពេលឃើញដើមទ្រូងណែនរបស់គេ។

សាច់ដុំរបស់គេរំញ័រនៅពេលគេឈានដល់រុញអាវយឺតរបស់ខ្ញុំចេញតាមពីលើក្បាល។ ក្នុងរយៈពេលតែប៉ុន្មានវិនាទីប៉ុណ្ណោះ យើងទាំងពីរអាក្រាតកាយនិងគ្មានដង្ហើម។

អង្គជាតិខាងក្រោមរបស់គេចង្អុលមកប៉ះពោះខ្ញុំទៀត។

លើកនេះមានអារម្មណ៍ថា វាជារបស់មួយដ៏ធំសម្បើម។

ខ្ញុំមានការងឿងឆ្ងល់ដែរថា តើសមឬអត់ដែលមិនសួរឈឺចាប់...ឬមកពីខ្ញុំស្រលាញ់និងមានតម្រូវការលើគេនេះពេក?

គំនិតទាំងអស់នោះកំពុងញាប់ញ័រនៅក្នុងចិត្តរបស់ខ្ញុំ ប៉ុន្តែវាត្រូវបានលុបចោលភ្លាមៗដោយភាពរីករាយជាងនេះ។

គេទាញរាងកាយអាក្រាតមកជិតហើយលុកលុយមកក្នុងច្រកចូលសាជាថ្មី។

ម្តងនេះមិនមែនលើជ្រុងសាឡុងទេ តែលើគ្រែធំដែលពួកយើងអាក្រាត១០០ភាគរយ។ មានអារម្មណ៍ថា ខ្ញុំសើមណាស់សម្រាប់គេ មានអារម្មណ៍ថាខ្ញុំមានតណ្ហាច្រើនបំផុត ដូចជាបានរង់ចាំគេពេញមួយជីវិតមកហើយ។

គ្រប់វិនាទីដែលកន្លងទៅខ្ញុំពិតជាចង់បានឱ្យគេចូលមកក្នុងតឡូវ ចូលម្តងទៀត ប៉ុន្តែខាងគេហាក់បីដូចជាកំពុងឆ្លៀតពេលដ៏ផ្អែមល្ហែម តាមដានចំណង់និងសេចក្តីស្កប់ស្កល់ដែលមើលមិនឃើញនៅលើដងខ្លួនរបស់ខ្ញុំដោយប្រើម្រាមដៃទះខ្ញុំថ្នមៗ ចូននៅជុំវិញចង្កេះខ្ញុំធ្វើឱ្យយើងនៅជិតគ្នាស្ទើរជាប់ជាប្រាណតែមួយ។

ទីបំផុត គេរុញដៃដែលទំនេរមកពីក្រោមខ្ញុំ ចាប់ត្រគាកខ្ញុំហើយច្របាច់យ៉ាងណែន។ ចុងរឹងរបស់គេត្រូវបានចុចមកទល់នឹងច្រកចូលរបស់ខ្ញុំ.....ទីនោះសើមនិងកក់ក្តៅ។ រាងកាយទាំងមូលរបស់ខ្ញុំបានផ្លាស់ប្តូរទៅជាចំណុះឱ្យគេបញ្ជាហើយឬទម្លាក់មកវិញតាមចិត្តគេ ព្រោះខ្ញុំរវល់ទន់ទៅក្នុងភាពស្រើបស្រាល តម្រូវការនិងហាក់អន្ទះសាមិនអាចរង់ចាំបានឡើយ។

ខ្ញុំមានអារម្មណ៍ថា គេដឹងថានេះជាលើកទីមួយរបស់ខ្ញុំ ទោះបីជាខ្ញុំមិនបានប្រាប់ក៏ដោយ។

បន្តិចម្តងៗគេរុញរាងកាយគេ ខ្ញុំលាតសន្ធឹងជាមួយនឹងការទទួលយកទាំងត្រដរឈឺនិងសប្បាយ ការរុញនីមួយៗរបស់គេ គឺជាអារម្មណ៍អស្ចារ្យលើសពីអ្វីដែលខ្ញុំអាចពណ៌នាបានត្រឹមតែពាក្យសរសេរ។

ខ្ញុំបិទភ្នែកឱបគេ គិតថាហោចណាស់ពេលនេះគេជារបស់ខ្ញុំ មិនថាគេមេបិសាច គេល្អនិងមានមេត្តាលើរាងកាយខ្ញុំ ឯខាងគេហាក់ដូចជាចេះអានចិត្តគំនិតរបស់ខ្ញុំបានយ៉ាងល្អឥតខ្ចោះ គេបន្ថែមមកជានិច្ចរាល់អ្វីដែលខ្ញុំត្រូវការ។

«មានអារម្មណ៍ល្អអូន?» គេរអ៊ូសួរជាមួយសព្ទសំឡេងហាត់គឃូស ជ្រៅពីក្នុងប្រអប់ដង្ហើមដែលហៀរមករកត្រចៀកនិងបំពង់កខ្ញុំតែអាចជ្រាតដល់បេះដូងខ្ញុំបាន។

បេះដូងនេះចង់ចងចាំគ្រប់ម៉ាត់របស់គេ មិនធុញទ្រាន់នឹងឡើយ។

«ចាស...» ខ្ញុំចាត់ចែងឆ្លើយដោយស្មោះចេញពីបេះដូងដូចគ្នាធ្វើឱ្យគេស្រវាឱបខ្ញុំដោយសោមនស្សហើយយើងទាំងពីរភ្ញាក់ផ្អើលជាមួយនឹងស្នេហាស្និតរមួតនេះ។

ទម្ងន់ពេញលេញរបស់គេ ឥឡូវកំពុងដំឡើងវាយបញ្ចូលមករកខ្ញុំ។ លើសពីការនៅខាងក្រោមញាប់ឡើងនិងធ្ងន់ហើយជ្រៅ។

ខ្ញុំស្រែកយំទាំងមានអារម្មណ៍ថាទឹកសើមខ្វាយចេញមកនៅចន្លោះភ្លៅរបស់ខ្ញុំ។

បបូរមាត់របស់ខ្ញុំស្រេកតែត្រូវគេក្រសោបមកវិញ ទាមទារការថើបដែលមិនអាចឃ្លាតគ្នា មុះមុតនិងស្វិតស្វាញ។ យើងទាំងពីរបាត់បង់ការគ្រប់គ្រង ដោយសាររលកតណ្ហាបាននាំយើងទៅកន្លែងមួយដែលយើងមិនធ្លាប់ទៅដល់ពីមុនមក។

មាត់របស់គេថើបបណ្តាតំណក់ទឹកភ្នែករបស់ខ្ញុំ បិទសំឡេងថ្ងូររបស់ខ្ញុំ នៅពេលដែលភាពជាបុរសរបស់គាត់បានសម្រុកចូលលឿននិងខ្លាំងក្លា ស៊ីជម្រៅ បន្សល់នូវសម្រែកអស់សំឡេងរបស់ខ្ញុំជាមួយនឹងការរុញនីមួយៗ។

ខ្ញុំដឹងថាបន្ទាប់ពីនេះទៅ ខ្ញុំនឹងមិនដូចខ្ញុំពីមុនទៀតទេ។ រាងកាយរបស់ខ្ញុំនឹងមិនអាចភ្លេចគេនេះបានដូចគ្នា។ ចិត្តគំនិតរបស់ខ្ញុំនឹងស្រណោះរង់ចាំគេ។

ខ្ញុំក៏មិនចង់គិតពីលទ្ធភាពដែលថានេះជាកំហុសធំមួយក្នុងជីវិតនោះដែរព្រោះជាអារម្មណ៍ល្អពេក ដែលសមនឹងថា មានកំហុសក៏មានទៅ ខ្ញុំមិនស្តាយក្រោយអ្វីទាំងអស់។

ខ្ញុំក៏មិនដឹង មិនអាចធានាថានេះជាស្នេហាពិត ឬគ្រាន់តែជាការរំជួលចិត្ត តែវាមិនសំខាន់ទេ។ ខ្ញុំនឹងគិតអំពីរឿងនោះនៅថ្ងៃស្អែក ប្រសិនបើខ្ញុំនឹងស្ថិតក្នុងស្ថានភាពណាមួយ ស្ងប់អាចគិតបានត្រឹមត្រូវ។

តែពេលនេះ មិនមែនទេ....

ខ្ញុំតោងគេដូចចង់ចងគេមកជាប់នឹងជីវិតរបស់ខ្ញុំ។ គេក៏ធ្វើដូចគ្នា។ រាងកាយខ្ញុំកន្ត្រាក់ហក់ចុះឡើងៗជុំវិញគល់មេជីវិតរបស់គេជាហេតុឱ្យខ្ញុំមានអារម្មណ៍ថា ពួកយើងជិតស្និទ្ធណាស់ ខ្ញុំមិនចង់ឱ្យគេឈប់...ឬឃ្លាតចេញពីខ្ញុំទេ។

ខ្ញុំមិនដឹងថា យើងនៅបែបនេះយូរប៉ុនណាទេ យើងទាំងពីរមិនព្រមផ្លាស់ទីឡើយ។ ការផ្លាស់ទីមានន័យថាបំបែកវេទមន្តនៃពេលបច្ចុប្បន្ន ត្រឡប់ទៅការពិតនៃជីវិតរស់នៅដែលសែនច្របូកច្របល់ ហើយចាំបាច់ត្រូវស្រាយចំណងបញ្ហា។

មនុស្សអម្បូរបន្តវេពាក់កណ្តាលមនុស្សនិងបិសាចជញ្ជក់ឈាម??? ហ៊ឹម!!!

ខ្ញុំមិនចង់ដឹងមិនចង់គិតរឿងទាំងអស់នោះទេឥឡូវនេះ។

ខ្ញុំមិនចង់បំផ្លាញភាពស្រស់ស្អាតនៃអ្វីដែលបានកើតឡើងឡើយ។ យើងគ្រប់គ្នា មិនដែលដឹងឡើយ ថានឹងមានអ្វីកើតឡើងនៅថ្ងៃស្អែកប៉ុន្តែខ្ញុំនឹងគិតពីវា នៅពេលដែលពេលវេលាមកដល់។

គេរអិលចេញពីខ្ញុំ ហើយរមៀលលើគ្រែ។

យើងទាំងពីរនៅតែដកដង្ហើមធំពោរពេញដោយអារម្មណ៍ឆាបឆ្អួល។ យើងទាំងពីរ ដូចជាមានអ្វីច្រើនណាស់ត្រូវនិយាយតែក៏គ្មានអ្នកណាចង់បញ្ចេញសំឡេងមកបំផ្លាញពេលវេលានេះឡើយ។

ដូច្នេះខ្ញុំបិទភ្នែក ដោយដឹងច្បាស់ថាពេលខ្ញុំបើកវាមកវិញ ពេលព្រឹកនឹងលេបយកគេទៅបាត់ទៅហើយ។ ខ្ញុំអស់មែនទែន! ខ្ញុំលូកដៃទៅរកគេឱបគេនិងដកដង្ហើមស្រូបក្លិនខ្លួនរបស់គេ....ដាក់ដៃលើទ្រូងគេដោយមានអារម្មណ៍ថា កក់ក្ដៅនិងសោកស្ដាយ។ បេះដូងគេនៅតែលោតញាប់និងញ័ររំជួយ។

ខ្ញុំមិនដឹងថាបានលង់លក់នៅពេលណាទេ ប៉ុន្តែពេលបើកភ្នែកមកវិញ ពិតជាដូចដែលខ្ញុំបានរំពឹងទុក។ ខ្ញុំនៅម្នាក់ឯងនៅលើគ្រែតែដោយហេតុផលខ្លះ ខ្ញុំនៅតែញញឹមសប្បាយចិត្តជាខ្លាំង។

## ខ្ញុំចាកចោលគេទាំងចិត្តនៅនឹងគេ-អេដម៉ុន

នេះជាព្រឹកព្រលឹមស្រាងៗ។

ខ្ញុំរកផ្លូវត្រលប់ទៅកាប់ជំរំលាក់ខ្លួនរបស់ក្រុមយើងទាំងចិត្តនៅអន្លាយៗ ដោយដឹងថា ការដើរចេញចោលស្រីជាទីស្រលាញ់ទាំងកណ្ដាលយប់ គឺជារបៀបគេចរបស់ជនកំសាក ប៉ុន្តែខ្ញុំក៏មិនប្រាកដថា តើខ្ញុំអាចសំកុកសម្លឹងមើលនាងស្រណោះបែបនេះដល់ពេលណា។

នាងជាមនុស្ស ខ្ញុំជាបិសាច។

យប់មិញនេះ នាងបានប្រគល់ព្រហ្មចារីរបស់នាងមកឱ្យខ្ញុំដោយគ្មានសញ្ញាសោកស្ដាយ។ ខ្ញុំស្អប់ខ្លួនឯងដែលបាត់ខ្លួនដូចចោរ តែខ្ញុំបន្តរំឭកខ្លួនឯងថា ការបែកគ្នាមកបែបនេះ ល្អប្រសើរសម្រាប់យើងទាំងពីរ។

មិនយូរប៉ុន្មាន ពេលកៀកទៅដល់ជំរំពួកយើង សង្កេតឃើញថាមានភាពចលាចលខ្លះពីចម្ងាយ។ ខ្ញុំប្រញាប់ចូលទៅ។ នៅទីនោះពេលខ្ញុំសម្គាល់ឃើញមានស្លាកស្នាមឈាមជាតំណក់។

ខ្ញុំដើរតាមជួរលោហិតទាំងអារម្មណ៍សង្ស័យនិងសៅហ្មង។ ប្រាកដណាស់ មិនមែនជារឿងល្អទេ។

«មានអ្វីកើតឡើង?» ខ្ញុំស្រែកសួរ។

ពួកគេទាំងអស់កំពុងចោមជុំវិញនរណាម្នាក់។ ពេលឮសំឡេងខ្ញុំដល់ គេនាំគ្នារើចេញ ញែកឱ្យខ្ញុំឆ្លងកាត់។ ហាលីមចុះមកដី។ Leoនៅក្បែរគាត់។ ឈាមកំពុងហូរពាសលើផ្ទៃមុខរបស់Leo។ ភ្នែកម្ខាងរបស់គេត្រូវបិទរបួស។

ដោយរន្ធត់ ខ្ញុំងាកទៅរកហាលីមចង់បានសេចក្ដីរាយការណ៍ បែរជាឃើញថាគាត់កំពុងប្រឹងប្រត់ចុចដៃទៅម្ខាងនៃដងខ្លួន។ ពេលនេះឯង ខ្ញុំសង្កេតឃើញថា គាត់ក៏កំពុងហូរឈាមយ៉ាងខ្លាំង។

ខ្ញុំខឹងសម្បាងាកមើលមនុស្សជុំវិញ។

Callum កំពុងរត់ត្រលប់មកយើងពីព្រៃដោយកាន់មែកឈើពណ៌ខៀវស្រងាត់នៅក្នុងដៃ។ គាត់ចាប់ផ្តើមបំបែករុក្ខជាតិនោះឱ្យទៅជាបំណែកតូចៗសម្រាប់បិទរបួស។ វាជាថ្នាំស័ក្តិសិទ្ធនៃអម្បូរយើង វាអាចបញ្ឈប់ការហូរឈាមបានយ៉ាងឆាប់រហ័សនិងផ្សះមានប្រសិទ្ធិភាព។

ខ្ញុំអាចមើលឃើញថា Halimឈឺចាប់ខ្លាំង។ គាត់កំពុងដកដង្ហើមយ៉ាងតឹងៗចរន្តឈាមស្តើងៗហូរតាមម្រាមដៃរបស់គាត់។

នៅពេលនោះ Kanoបង្ហាញខ្លួននៅក្បែរខ្ញុំ បន្ទាប់មកស្ទុះចូលទៅជួយCallumក្នុងកិច្ចព្យាបាល។

ឡេអូប្រាប់ខ្ញុំថា៖

«មេ! យើង... រងការវាយប្រហារ»

ថាបានប៉ុណ្ណឹង ក៏បន្ទាបក្បាលរបស់គាត់ទៅក្នុងដៃ ហាក់ដូចជាធ្ងន់ពេកមិនអាចនឹងនរបាន។

«ក្រុមណា? ប៉ូលិសឬពួកបន្តវេន?»

ខ្ញុំសួរ ប៉ុន្តែវាជាសំណួរដែលមិនចាំបាច់។ គ្មានអ្នកណាអាចវាយប្រហារពួកយើងបានធ្ងន់យ៉ាងនេះទេបើគ្មានកាំភ្លើង មានតែពួកអម្បូរមនុស្សកាត់បិសាច។

Leo បន្តថា៖

«យើងបានជំពប់ចួបពួកបន្តវេនដោយចៃដន្យ!»

គាត់និយាយយឺតៗហាក់បីដូចជាពាក្យនីមួយៗពិបាកបញ្ចេញសំឡេងមកក្រៅពិតមែន។ ហើយគាត់ត្រូវប្រើថាមពលខួរក្បាលទាំងអស់មករាយការណ៍ ដែលជាហេតុធ្វើឱ្យរបួសកាន់តែឈឺចាប់។

«យើងសង្ឃឹមថា ពួកគេមិនបានកត់សម្គាល់ឃើញយើងនោះទេ ប៉ុន្តែពួកគេឆ្នក់!!!»

ខ្ញុំដាក់ដៃលើស្មាគាត់ រួចបន្ទាបខ្លួនទៅជិត។ ខ្ញុំប្រាប់គាត់ថា៖

«ស្ថានការណ៍អាចថាកាន់តែអាក្រក់ទៅៗហើយ! យើងត្រូវប្រុងប្រយ័ត្នឱ្យបានច្រើនជាងនេះ! ពួកគេប្រាកដជាផ្សព្វផ្សាយអំពីវត្តមានពួកយើង!»

កាណូស្រែកឡើងដោយឈឺចាប់ថា៖

«ពួកវានោះ មិនចង់ឱ្យយើងរកបានអណ្តូងវេទនមន្តទេ ព្រោះគេដឹងថា វាមានន័យយ៉ាងណាសម្រាប់យើងបន្តវង់ត្រកូល! ប៉ុន្តែយើងនឹងរកដល់តែឃើញ មិនថាមានអ្វីកើតឡើងទេ»។

ខ្ញុំច្របាច់ស្មារបស់ឡេអូមួយលើកទៀតជាការលើកទឹកចិត្តគេ បន្ទាប់មកខ្ញុំគេចដើរចេញដោយត្រូវការពេលខ្លះសម្រាប់ខ្លួនឯងមកប្រឈមគិតនឹងស្ថានការណ៍ស្មុគស្មាញ។

ដំបូងឡើយ ខ្ញុំជឿថាអ្នកប្លូវេនបានដឹងថាយើងនៅទីនេះ។ ខ្ញុំប្រាកដថា Bianca មិនបានក្បត់ឬកុហកខ្ញុំទេ។ តែអាចថាមាននរណាម្នាក់ មកដល់ឃើញយើង អាចជាមិត្តភក្តិរបស់នាងដែលបានក្បត់នាង។

យ៉ាងណាមិញ ខ្ញុំចង់គិតកុហកខ្លួនឯងដោយរំពឹងថា ពួកអម្បូរបន្តវេនច្រើមនមានភាពស្មោះត្រង់ចំពោះសុខុមាលភាពនៃត្រកូលច្រើនជាងមនុស្សធម្មតា បើពួកគេថាមិននិយាយ គឺគេមិននិយាយទេ។

ខ្ញុំដកដង្ហើមធំ មើលធម្មជាតិព្រៃភ្នំពីចម្ងាយដែលចោមព័ទ្ធទីក្រុងនេះ។

អណ្តូងអាចនៅគ្រប់ទីកន្លែង ទីណាមួយ ជុំវិញយើងនេះឯង។

នរក!!!! យើងអាចនឹងដើរឆ្លងកាត់វាហើយផងក៏មិនដឹងដែរ។

បញ្ហាគឺមកពីក្រុម យើងមានគំនិតមិនច្បាស់លាស់អំពីកន្លែងដែលវាអាចមាន។ ពេលវេលាបានកន្លងផុតទៅច្រើនពេកហើយ ពេលខ្លះខ្ញុំឆ្ងល់ថា តើយើងខ្វះខ្វាយទេ ដែលមកបង្អង់នៅរុករកទាំងគ្មានតម្រុយបែបនេះ នៅទីនេះ?

«មេដឹកនាំកំពុងស្មុគស្មាញ?»

ជាសំឡេងរបស់ Kano ពីខាងក្រោយខ្ញុំ។

ខ្ញុំនិយាយតបៈ

«គ្នាយើងស្ទើរតែបាត់បង់ជីវិតដល់ទៅពីរនាក់! សប្បាយចិត្តម៉េច?»

ឆ្លើយផងខ្ញុំព្យាយាមកុហកខ្លួនឯងផង។ ក្រុមខ្ញុំកំពុងមានរឿង ឯខ្ញុំបានធ្វើរឿងស្រីប្រុសមួយអាត្មានិយមទៅវិញ។ គ្រប់ពេលវេលាខ្ញុំនឹកតែដល់ពេលដែលបាន fuck នាង។

ក្លិននាង រសជាតិនាង នៅជិតក្នុងបេះដូងនេះ។

ខ្ញុំចង់សារភាពទុក្ខព្រួយទាំងនេះប្រាប់ទៅ Kano តែហាក់ដូចជាមានអ្វីមួយបានរារាំងខ្ញុំពីការហើបមាត់និយាយអំពីស្នេហាខ្ញុំនិងមនុស្សា។

ធ្វើដូច្នេះល្អជាង ទុកBiancaគឺជាអាថ៌កំបាំងមួយ ត្រូវរក្សាការសម្ងាត់។

ដោយច្បួតមុខ Kano បានធានាចំពោះខ្ញុំឡើងថាៈ

«កំហុសមួយនេះ នឹងមិនអនុញ្ញាតឲ្យកើតឡើងម្តងទៀតទេព្រះអង្គរបស់ពួកយើង! ខ្ញុំនឹងការពារពួកយើង ឱ្យបានល្អបំផុត!»

«មិនមែនជាកំហុសអ្នកណាម្នាក់ទេ បើមែន ជាកំហុសខ្ញុំ!» ខ្ញុំបដិសេធការទទួលរបស់កាណូដោយគ្រវីក្បាល។ មិនបង្អង់ ខ្ញុំឧទានដោយស្រងូតៈ

«តើពេលណាដែលបិសាចជញ្ជក់ឈាមនិងអ្នកប្ដូរវេន អាចអង្គុយជជែកនៅក្នុងបន្ទប់តែមួយដោយសន្តិភាព?»

ឮហើយក៏Kano មិននិយាយអ្វីចំពោះមតិនេះទេព្រោះយើងទាំងពីរដឹងចម្លើយ។ រឿងបែបនេះមិនអាចកើតឡើងបានជាដាច់ខាត វាមិនដែលទេ!

ខ្ញុំសង្ស័យថា ពួកព្រឹទ្ធាចារ្យនៃអម្បូរអមនុស្សនិងមនុស្សពាក់កណ្ដាល មានឆន្ទៈចង់ជួបចរចាជាមួយយើងមិនស្មោះ ព្រោះពួកគេត្រូវការស្ទាក់ចាប់យើងនិងផ្ដាច់ពូជបិសាចជញ្ជក់ឈាម។ ខ្ញុំប្រាប់សហការីតិចៗ៖

«អូខេ បេសកកម្មចម្បង យើងត្រូវបន្តស្វែងរកអណ្ដូងនោះ»

«ប្រសិនបើយើងមានផែនទី...» Kano ត្អូញដោយដកដង្ហើមធំ។

ខ្ញុំដឹងថាគាត់កំពុងនិយាយអំពីផែនទីអ្វី។ អ្វីដែលយើងដឹងអំពីអណ្ដូងនោះគឺជាអ្វីដែលយើងបានឮពីរឿងចាស់ៗ។

ជាការពិតណាស់ មានកំណែរាប់ពាន់ ក្នុងព័ត៌មានមួយលើកៗ ប៉ុន្តែអ្នករាល់គ្នាដឹងថាកំណែមួយនេះគឺជាកំណែចាស់បំផុតគឺដំណឹងដែលថា អណ្ដូងនោះមានផែនទីទៅដល់។

អ៊ុចឹង!!!

...មានផែនទីមួយពិតមែន តែមិនដឹងរសាត់ដល់ណាធ្លាក់ក្នុងដៃអ្នកណា។

មានគេនិយាយថា កាលឆ្នាំ៦៦៨ ផែនទីបុរាណ បានធ្លាក់ក្នុងដៃជាកម្មសិទ្ធិរបស់មេបិសាចម្នាក់ ដែលក្បត់ក្រុម ចង់ឡើងសោយរាជ្យ ហើយត្រូវល្បួងដោយក្រុមអម្បូរផ្សេង ដែលគ្រប់គ្នាតាមប្រើគ្រប់មធ្យោបាយតាមលួចវា។

ក្រោយមកមិនមានអ្នកណាដឹងច្បាស់អំពីពីផែនទីនោះទៀតឡើយ។ មានទាំងបិសាចជញ្ជក់ឈាម និងអ្នកបន្តវេននៃអម្បូរមនុស្សចចក មនុស្សខ្លាឃ្មុំ យក្សា និងពួកកុលសម្ព័ន្ធឆីមនុស្ស បានផ្សាយពាក្យចចាមអារាមជានិច្ចជាកាលថា បានឃើញផែនទីនៅនឹងអ្នកនេះឬអ្នកនោះ ប៉ុន្តែគ្មាននរណាម្នាក់អាចបញ្ជាក់បានថា ការពិត នៅឯណានោះឡើយទេ។

«ជួយមើលរបួសពួកគេឱ្យល្អ!»

កាណូលំឱនកាយទទួលបទបញ្ជានេះនិងបានចាកចេញ។ ពេលខ្ញុំបិទភ្នែក ខ្ញុំអាចមើលឃើញតែស្រមោលនាង។ ខ្ញុំអាចឮបេះដូងក្ដៅរំជួលរបស់នាង។ ខ្ញុំអាចមានអារម្មណ៍អំពីនាង ក្លិន ស្នាមញញឹមនិងរសជាតិ....។

សត្វនៅខាងក្នុងព្រលឹងខ្ញុំកំពុងញាប់ញ័រ ចង់ហែកទ្រុង ទាមទារឱ្យបានតែឃើញនាងម្ដងទៀត

ស្ងាត់ៗខ្ញុំសន្យាក្នុងចិត្តថា នឹងទៅរកនាងយប់នេះផងដែរ។

ខ្ញុំអាចសួរនាងអំពីផែនទីនិងអណ្ដូងវេទមន្តក្រែងមិត្តៗអម្បូរផ្សេងរបស់នាងធ្លាប់បង្ហើប ប្រសិនបើពួកគេដឹង។

ពេលយើងរកឃើញអណ្ដូងហើយ យើងនឹងទៅបន្តបេសកកម្មសម្រាប់បុព្វបុរសរបស់យើង។ ពេលនោះ បើនាងមិនចង់មកនៅជិតខ្ញុំទេ ខ្ញុំនឹងព្រមបំភ្លេចនាង។ មានន័យថាឆ្ងាយបេះដូងឃើប៉ុនណាក៏ព្រម ខ្ញុំគ្រាន់តែចង់ឱ្យគេបានសុខ។

«ទេ» ខ្ញុំគ្រវីក្បាលព្យាយាមនិយាយឱ្យជឿជាក់ថាអាចទៅរួច គឺព្យាយាមតាមដែលអាចធ្វើទៅបាន

សម្លឹងទៅក្រៅជម្រក នៃជំរុំដែលពេញប្រៀបដោយព្រឹក្សាលតាវល្លិ។ ចិត្តខ្ញុំរាយមាយ ....ជាធម្មតា ព្រៃគឺជាកន្លែងមិត្តភាព ជាសុវត្ថិភាពសម្រាប់បិសាចជញ្ជក់ឈាម។

ព្រៃព្រឹក្សា បានជួយលាក់បំពួនយើងឱ្យចាកឆ្ងាយពីភ្នែកមនុស្សនិងឬអម្បូរសត្វសាហាវដទៃៗទៀតដែលចង់ធ្វើបាបយើង។ ការប្រទូស្តរាយគ្មានសេចក្តីសុខ ដំណើរការអស់ជាច្រើនសតវត្សមកហើយ។ យ៉ាងណាមិញលើកនេះ ខ្ញុំមិនមានអារម្មណ៍ថា ព្រៃជុំវិញជំរំនេះកំពុងការពារពួកយើងទៀតនោះទេ។ វាជាអារម្មណ៍សុវត្ថិភាពមិនពិតមួយដែលខ្ញុំមិនទុកចិត្តស្ថានការណ៍ទៀតនោះឡើយ។

ខ្យល់បោកសន្ធឹកកាត់តាមមែកឈើ។

ស្រាប់តែទទួលអារម្មណ៍ថា វាយោហាក់បីដូចជាកំពុងខ្សឹបប្រាប់ខ្ញុំអ្វីមួយ....ជាការព្រមានគំរាមកំហែងដូចជាកំពុងជំរុញប្រាប់ពួកយើងឱ្យចាកចេញ?

ទ្រូងនេះញាប់ញ័រពេលគិតអំពីអ្វីដែលអាចនឹងកើតមានឡើងប្រសិនបើយើងប៉ះគ្នាជាមួយក្រុមអ្នកបន្តវេន។ យើងមានចំនួនតិច ពួកគេច្រើនលើសលប់។ ពួកគេនឹងស៊ីយើងទាំងរស់។ ពួកគេនឹងដុតយើងនៅបង្គោល ហើយនេះមិនមែនជាលើកទីមួយទេ វាកើតឡើងយ៉ាងឃោរឃៅរួចមកហើយ។

ខ្ញុំបិទភ្នែក ព្យាយាមរំងាប់បំបិទចោលរាល់សព្ទសំឡេងស្រែករបស់បិសាចជញ្ជក់ឈាមជាច្រើននាក់ដែលបានស្លាប់នៅដៃអ្នកបន្តវេននិងប៉ូលិស។

ទុក្ខវេទនាជាច្រើនតំណមកនេះ ស្ថិតនៅក្នុងចរន្តឈាមរបស់ខ្ញុំ លងព្រលឹងខ្ញុំ ទោះជាខ្ញុំចង់បញ្ចប់វាប៉ុនណាក៏ដោយ ក៏គ្មានវិធីដើម្បីសម្រេចបាននូវរឿងសន្តិភាពមួយនេះឱ្យអម្បូរពួកយើងដែរ។

ឈាមមនុស្សច្រើនពេកត្រូវបានពួកយើងបង្ហូរចិញ្ចឹមជីវិត កំហុសជាច្រើនត្រូវបានធ្វើឡើង ហើយគ្មានយើងស្រេកឃ្លាននិងគ្មានសិទ្ធិអាចផ្លាស់ប្តូរការពិតនេះបានទេដរាបណាគ្មានទឹកអណ្តូងនោះ។ ប៉ុន្តែ....មហន្តរាយគឺថា បើគ្មានអណ្ដូងនោះឆាប់ៗនេះទេ ពូជពង្សយើងនឹងត្រូវវិនាស។

យើងកាន់តែចុះខ្សោយជាមួយនឹងបណ្តាថ្ងៃដែលឆ្លងកាត់។

ខ្ញុំដឹងថាយើងទាំងអស់គ្នាកំពុងព្យាយាមធ្វើពុតដូចមិនមានអ្វីកើតឡើង ប៉ុន្តែការបិទភ្នែកមើលឃើញការពិតទាំងថ្ងៃទាំងយប់ គឺជាទុក្ខសោកធំបំផុតមួយ។

ខ្ញុំស្រូបចូលយ៉ាងជ្រៅ ព្យាយាមចាប់ក្លិនក្រអូបនានាក្នុងធម្មជាតិមករំងាប់ចិត្តខឹង ប៉ុន្តែគ្មានអ្វីក្រៅពីក្លិននៃទីរហោស្ថានជុំវិញខ្លួនយើង។ គ្មានក្លិនពួកអ្នកបន្តវេនមកជិតៗទេ ប៉ុន្តែក៏មិនមានន័យថា យើងមានសុវត្ថិភាពនោះដែរ។